Health Plan of San Joaquin

# សេចក្តីជូនដំណឹង អំពីការអនុវត្តន៍ភាពឯកជន

ចាប់ប្រតិបត្តិ ៖ ថ្ងៃទី 1 ខែកក្កដា ឆ្នាំ 2004

**សេចក្តីជូនដំណឹងនេះគឺរៀបរាប់ពីរបៀបពត៌មានសុខភាពអំពីរូបអ្នក អាចបានប្រើ និងបានបញ្ចេញ ព្រមទាំងពណ៌នាពីរបៀបដែលអ្នកអាចទទួលពត៌មាននេះ ។ សូមពិនិត្យមើលវាឲ្យបានហ្មត់ចត់ ។**

គំរោងសុខភាព (Health Plan) ផ្តល់ការថែរក្សាសុខភាពឲ្យអ្នក សំរាប់កម្មវិធី Medi-Cal ។ ច្បាប់រដ្ឋ និងច្បាប់រដ្ឋបាលសហព័ន្ធ បានដំរូវឲ្យយើងការពារពត៌មានសុខភាពរបស់អ្នក ។ ហើយយើងក៏ត្រូវតែផ្តល់សេចក្តីជូនដំណឹងនេះឲ្យអ្នក ដើម្បីជំរាបអ្នកឲ្យដឹងពីរបៀបដែលយើងអាចប្រើប្រាស់ និងចែកចាយពត៌មានរបស់អ្នក និងប្រាប់អំពីសិទ្ធិរបស់អ្នកមានអ្វីខ្លះ ។

### ពត៌មានរបស់អ្នកគឺជាការផ្ទាល់ខ្លួន និងជាឯកជន ។

យើងទទួលពត៌មានអំពីរូបអ្នក ពី Medi-Cal បន្ទាប់ពីអ្នកបានក្លាយជាមានសិទ្ធិទទួល និងចុះឈ្មោះក្នុងគំរោងសុខភាពរបស់យើង ។ យើងក៏ទទួលពត៌មានសុខភាព ពីគ្រូពេទ្យរបស់អ្នក ពីមន្ទីរពិនិត្យរោគា មន្ទីរពិសោធន៍ និងពីមន្ទីរពេទ្យផងដែរ ប្រយោជន៍សំរាប់ការយល់ព្រម និងបង់ថ្លៃការថែរក្សាសុខភាពរបស់អ្នក ។

## របៀបយើងអាចប្រើប្រាស់ និងចែកចាយពត៌មានអំពីរូបអ្នក

ពត៌មានរបស់អ្នក អាចបានប្រើ ឬបានចែកចាយដោយគំរោងសុខភាព សំរាប់តែមូលហេតុជាប់ទាក់ទងផ្ទាល់ចំពោះកម្មវិធី Medi-Cal ប៉ុណ្ណោះ ។ ពត៌មានដែលយើងប្រើ និងចែកចាយមានរាប់បញ្ចូល ប៉ុន្តែមិនកំរិតចំពោះ ៖

- ឈ្មោះរបស់អ្នក
- អាសយដ្ឋាន និង
- បែបផែននៃការថែរក្សាសុខភាពដែលអ្នកបានទទួល

វិធានការខ្លះយើងបានធ្វើ នៅពេលយើងធ្វើក្នុងនាមជាគំរោងសុខភាព Medi-Cal គឺមាន ៖

- ការឆែកមើលសិទ្ធិទទួល និងការចុះឈ្មោះរបស់អ្នក ។
- ការយល់ព្រម និងការបង់ថ្លៃសំរាប់ការបំរើ Medi-Cal ។
- ទូរស័ព្ទមករំលឹកអ្នក អំពីការណាត់ពេលជួបជាមួយគ្រូពេទ្យរបស់អ្នក ។
- ការស៊ើបអង្កេត ឬការផ្តន្ទាទោសរឿងរ៉ាវ Medi-Cal (ដូចជាការលួចបន្លំ) ។
- ការឆែកមើលគុណភាព នៃការថែរក្សាដែលអ្នកទទួល ។
- ការសំរបសំរួល ការថែរក្សាដែលអ្នកទទួល ។
- ការផ្តល់ពត៌មានឲ្យអ្នក ដើម្បីជួយចាត់ចែងជំងឺធ្ងន់ធ្ងរ ។
- ការចែកចាយពត៌មានជាមួយភ្នាក់ងារសុខភាពសាធារណៈ នៅពេលណាច្បាប់បានអនុញ្ញាត ។

**<u>ឧទាហរណ៍មួយចំនួន :</u>**

1. **<u>សំរាប់ការព្យាបាល :</u>** អ្នកអាចត្រូវការព្យាបាលសុខភាព ដែលដំរូវឲ្យយើងយល់ព្រមចំពោះការថែរក្សាជាមុន ។ ដូច្នោះហើយយើងនឹងចែកចាយពត៌មានជាមួយគ្រូពេទ្យ មន្ទីរពេទ្យ និងជាមួយអ្នកផ្សេងៗទៀត ប្រយោជន៍ឲ្យអ្នកទទួលការថែរក្សាដែលអ្នកត្រូវការ ។

2. **<u>សំរាប់ការបង់ប្រាក់ :</u>** គំរោងសុខភាព នឹងពិនិត្យមើលឡើងវិញ ឬយល់ព្រម និងបង់ថ្លៃការថែរក្សាសុខភាព ដែលគេទារយើង សំរាប់ការព្យាបាលអ្នក ។ នៅពេលណាយើងធ្វើដូច្នេះ នោះយើងត្រូវការចែកចាយពត៌មាន ជាមួយគ្រូពេទ្យ ឬមន្ទីរពិនិត្យរោគ និងអ្នកផ្សេងទៀតដែលចេញសំបុត្រទារប្រាក់ពីយើងសំរាប់ការថែរក្សាអ្នក។ ហើយយើងអាចបញ្ជូនសំបុត្រទារប្រាក់ទៅគំរោងសុខភាពផ្សេងៗទៀត ឬក៏អង្គការផ្សេងៗឲ្យគេបង់ប្រាក់ ។

3. **<u>សំរាប់ដំណើរការថែរក្សាសុខភាព :</u>** យើងអាចប្រើពត៌មាននៅក្នុងឯកសារសុខភាពរបស់អ្នក ដើម្បីវិនិច្ឆ័យ គុណភាពនៃការថែរក្សាសុខភាពដែលអ្នកទទួល ។ យើងក៏អាចនឹងប្រើពត៌មាននេះនៅក្នុងការជំរះបញ្ជីប្រាក់ ការលួចបន្លំ និងការរំលោភកម្មវិធី ឬការគ្រោងការ និងការចាត់ចែងទូទៅផងដែរ ។

# ការប្រើពត៌មានសុខភាពរបស់អ្នក សំរាប់ការផ្សេងៗទៀត

1. ជួនកាលតុលាការនឹងបញ្ជាឲ្យយើងផ្តល់ពត៌មានសុខភាពរបស់អ្នក ។ យើងក៏នឹងឲ្យពត៌មាននោះទៅតុលាការ ទៅអ្នកស៊ើបអង្កេត ឬមេធាវី បើសិនជាអំពីដំណើរការនៃ Medi-Cal ។ ការនេះអាចជាប់ទាក់ទងនឹងការលួចបន្លំ ឬការចាត់វិធានការទាមទារយកប្រាក់មកវិញពីអ្នកផ្សេងៗ ដែល Medi-Cal បានបង់ថ្លៃការថែរក្សាសុខភាពរបស់អ្នក ។

2. រូបអ្នក ឬគ្រូពេទ្យរបស់អ្នក ឬមន្ទីរពេទ្យ និងអ្នកផ្តល់ការថែរក្សាសុខភាពផ្សេងៗទៀត អាចតវ៉ានឹងការសំរេចផ្សេងៗដែលបានធ្វើអំពីការទាមទារឲ្យសងប្រាក់ សំរាប់ការថែរក្សា Medi-Cal របស់អ្នក ។ ពត៌មានសុខភាពរបស់អ្នកអាចនឹងបានប្រើ សំរាប់តវ៉ាអំពីការសំរេចទាំងនេះ ។

3. យើងក៏អាចចែកចាយពត៌មានសុខភាពរបស់អ្នក ជាមួយភ្នាក់ងារ និងអង្គការផ្សេងៗ ដែលឆែកមើលរបៀបគំរោងសុខភាពរបស់យើង កំពុងតែផ្តល់ការបំរើថែរក្សាបានល្អក៏វិតណា ។

4. យើងក៏នឹងចែកចាយពត៌មានសុខភាពរបស់អ្នក ជាមួយអ្នករដ្ឋការរដ្ឋបាលសហព័ន្ធ នៅក្នុងករណីដ៏កម្រមាន ដែលជាប់ទាក់ទងនឹងសន្តិសុខជាតិ ដីរាប់ទាំងសេចក្តីការពារប្រធានាធិបតីសហរដ្ឋអាមេរិក ។

5. យើងត្រូវតែចែកចាយពត៌មានសុខភាពរបស់អ្នក ជាមួយរដ្ឋាភិបាលសហព័ន្ធ នៅពេលគេឆែកមើលការប្រតិបត្តិច្បាប់ភាពឯកជនបានស្របតាមក៏វិតណា ។

# នៅពេលត្រូវការសេចក្តីអនុញ្ញាត ជាលាយល័ក្ខអក្សរ

បើយើងចង់ប្រើពត៌មានរបស់អ្នក សំរាប់មូលហេតុណាមួយដែរពុំបានចុះរាយនៅខាងលើទេ នោះយើងត្រូវតែទទួលការអនុញ្ញាតពីអ្នក<u>ជាលាយល័ក្ខអក្សរ</u> ។ បើអ្នកផ្តល់ការអនុញ្ញាតឲ្យយើង អ្នកក៏អាចសរសេរសំបុត្រសុំដកយកវិញ នៅពេលណាក៏បានដែរ ។

## តើសិទ្ធិភាពឯកជនរបស់អ្នក មានអ្វីខ្លះ?

- អ្នកមានសិទ្ធិស្នើយើង មិនឲ្យប្រើ ឬចែកចាយពត៌មានការថែរក្សាសុខភាពផ្ទាល់ខ្លួនរបស់អ្នក តាមរបៀបដែលបានរៀបរាប់នៅខាងលើ ។ យើងប្រហែលជាពុំអាចយល់ព្រមចំពោះសំណើរបស់អ្នកឡើយ ។

- អ្នកមានសិទ្ធិស្នើឲ្យយើងទាក់ទងមកអ្នក តែតាមរយៈសំបុត្រ ឬនៅអាសយដ្ឋានផ្សេងទៀត ឬតាមប៉ុស្តិសំបុត្រ ឬតែតាមទូរស័ព្ទប៉ុណ្ណោះ ។ យើងនឹងយល់ព្រមចំពោះសំណើដែលសមហេតុផល នៅពេលវាជាការចាំបាច់ ដើម្បីការពារភាពសុខសាន្តរបស់អ្នក ។

- រូបអ្នក និងអ្នកតំណាងផ្ទាល់ខ្លួនរបស់អ្នក មានសិទ្ធិយកច្បាប់ចំឡងនៃពត៌មានសុខភាពរបស់អ្នក ។ យើងនឹងផ្ញើក្រដាសបំពេញមួយទៅឲ្យអ្នកបំពេញ ហើយអាចឲ្យអ្នកបង់ថ្លៃការថតចំឡង និងការផ្ញើឯកសារ ។ (យើងប្រហែលជាពុំឲ្យអ្នកឃើញផ្នែកខ្លះនៃឯកសាររបស់អ្នក សំរាប់មូលហេតុដែលច្បាប់បានអនុញ្ញាត) ។
  សារៈសំខាន់ : គំរោងសុខភាពពុំមានច្បាប់ចំឡងនៃឯកសារសុខភាពរបស់អ្នកទាំងអស់ទេ ។ បើសិនជាអ្នកចង់មើលវា ឬចង់បានវាមួយច្បាប់ ឬបើអ្នកចង់ផ្លាស់ប្តូរឯកសារសុខភាពរបស់អ្នក សូមទាក់ទងទៅគ្រូពេទ្យរបស់អ្នក ឬមន្ទីរពេទ្យ ឬមន្ទីរពិនិត្យរោគរបស់អ្នក ។

- អ្នកមានសិទ្ធិស្នើ ថាពត៌មាននៅក្នុងឯកសាររបស់អ្នកគប្បីតែបានកែប្រែ បើវាមិនត្រឹមត្រូវ ឬមិនចប់សព្វគ្រប់នោះទេ ។ យើងប្រហែលជាពុំអាចធ្វើតាមសំណើរបស់អ្នកបានទេ បើសិនជា :
  - គំរោងសុខភាពមិនបានបង្កើត ឬមិនបានទុកពត៌មាននោះ ឬ
  - យើងជឿថាវាត្រឹមត្រូវ និងចប់សព្វគ្រប់ ។

  បើយើងមិនធ្វើការផ្លាស់ប្តូរអ្វីដែលអ្នកស្នើទេ អ្នកអាចស្នើឲ្យយើងពិនិត្យការសំរេចរបស់យើងឡើងវិញ ។ អ្នកក៏អាចនឹងត្រូវផ្ញើសេចក្តីថ្លែងការណ៍មួយ ដោយនិយាយថាអ្នកមិនយល់ស្របជាមួយឯកសាររបស់យើង ហើយយើងនឹងទុកសេចក្តីថ្លែងការណ៍នោះ នៅជាមួយឯកសាររបស់អ្នក ។

- បើយើងចែកចាយពត៌មានសុខភាពរបស់អ្នក បន្ទាប់ពីថ្ងៃទី 14 ខែមេសា ឆ្នាំ 2003 អ្នកមានសិទ្ធិស្នើយកបញ្ជី :
  - យើងបានចែកចាយពត៌មានជាមួយអ្នកណា
  - យើងបានចែកចាយវានៅពេលណា
  - សំរាប់មូលហេតុអ្វី ហើយ
  - ពត៌មានអ្វីដែលបានចែកចាយ ។

សារៈសំខាន់ : បញ្ជីនេះនឹងមិនរាប់ទូវពត៌មានបានចែកចាយជាមួយអ្នក ដោយមានការអនុញ្ញាតពីអ្នក ឬសំរាប់ការព្យាបាល ការបង់ប្រាក់ ឬសំរាប់ដំណើរការថែរក្សាសុខភាព ដូចបានរៀបរាប់នៅទំព័រទីពីរឡើយ ។

## តើអ្នកទាក់ទងមកយើង ដើម្បីប្រើសិទ្ធិរបស់អ្នក ដោយរបៀបណា?

អ្នកមានសិទ្ធិស្នើយកក្រដាសចំឡងនៃសេចក្តីជូនដំណឹងការអនុវត្តន៍ភាពឯកជននេះបាន ។ អ្នកក៏អាចរកឃើញសេចក្តីជូនដំណឹងនេះនៅក្នុងអន្តរបណ្តាញរបស់យើងនៅឯ www.hpsj.com ផងដែរ ។ បើអ្នកចង់ប្រើសិទ្ធិភាពឯកជនអ្វីមួយ ដែលបានពន្យល់ក្នុងសេចក្តីជូនដំណឹងនេះ សូមទូរស័ព្ទ ឬមកជួប :


Health Plan of San Joaquin
1550 W. Fremont Street, Suite 200
Stockton, CA 95203
(209) 942-6320

# ការត្អូញត្អែរ

បើអ្នកជឿថា យើងមិនបានការពារភាពឯកជនរបស់អ្នកទេ ហើយមានបំណងត្អូញត្អែរ នោះអ្នកអាចធ្វើពាក្យត្អូញត្អែរបាន ដោយទូរស័ព្ទ ឬសរសេរពាក្យប្តឹងទៅអ្នករដ្ឋការភាពឯកជន (Privacy Officer) របស់យើង តាមអាសយដ្ឋាន :

Health Plan of San Joaquin
ATTN: Privacy Officer
P.O. Box 30490
Stockton, CA 95213
(209) 942-6300 ឬ (800) 430-7077 TTY/TDD

ឬ

Privacy Officer
c/o Office of Legal Services
California Department of Health Services
P.O. Box 942732
Sacramento, CA 94234-7320
(916) 255-5259

ឬអ្នកទាក់ទងភ្នាក់ងារនៅខាងក្រោម :

(លេខាធិការសហរដ្ឋ នៃក្រសួងសុខាភិបាល និងកិច្ចការមនុស្សជាតិ)
**Secretary of the U.S. Department of Health and Human Services**
Office for Civil Rights (ការិយាល័យសំរាប់សិទ្ធិពលរដ្ឋ)
Attention: Regional Manager (អ្នកចាត់ការភូមិភាគ)
50 United Nations Plaza, Room 322
San Francisco, CA 94102
ដើម្បីឲ្យបានពត៌មានថែមទៀត សូមទូរស័ព្ទទៅលេខ (800) 368-1019

ឬ

U.S. Office for Civil Rights លេខ (866) OCR-PRIV (866-627-7748)
ឬ (866) 788-4989 TTY

# ប្រើសិទ្ធិរបស់អ្នក ដោយគ្មានការភ័យខ្លាចអ្វី

គំរោងសុខភាពមិនអាចដកអត្ថប្រយោជន៍ការថែរក្សាសុខភាពរបស់អ្នកចេញឡើយ ឬអាចចាត់វិធានការអ្វីប្រឆាំងនឹងអ្នកឡើយ បើអ្នកជ្រើសធ្វើពាក្យត្អូញត្អែរ ឬបើអ្នកប្រើសិទ្ធិការអនុវត្តន៍ភាពឯកជនអ្វីមួយ ដែលមាននៅក្នុងនៃសេចក្តីជូនដំណឹងនេះ ។

# ការផ្លាស់ប្តូរសេចក្តីជូនដំណឹង នៃការអនុវត្តន៍ភាពឯកជន

គំរោងសុខភាពត្រូវតែគោរពសេចក្តីជូនដំណឹងដែលមាននៅបច្ចុប្បន្ននេះ ។ យើងមានសិទ្ធិផ្លាស់ប្តូរការអនុវត្តន៍ភាពឯកជនទាំងនេះ ។ បើយើងផ្លាស់ប្តូរក្រោយពីថ្ងៃទី 14 ខែមេសា 2003 យើងនឹងកែប្រែសេចក្តីជូនដំណឹងនេះ ហើយផ្ញើវាទៅឲ្យអ្នកភ្លាម ។

# សំណួរផ្សេងៗ

បើអ្នកមានសំណួរអ្វីអំពីសេចក្តីជូនដំណឹងនេះ ហើយចង់បានពត៌មានថែមទៀត សូមទាក់ទងទៅផ្នែកបំរើសមាជិក (Member Services) តាមអាសយដ្ឋាន និងលេខទូរស័ព្ទដែលមាននៅលើទំព័រទីបី ។